0:00

- ជំរាបសួរ សហគមន៍ LBUSD

0:03

តើអ្នកគួរជឿទេថា រដូវក្តៅ គឺជិតមកដល់ហើយនោះ?

0:06

ខ្ញុំឈ្មោះ Stephanie Heilig

0:07

ជានាយកគ្រប់គ្រងការិយាល័យទំនាក់ទំនង

0:09

សមធម៌ និងភាពជាដៃគូ

0:11

នៅពេលដែលអ្នកមាន ឬ គ្មានគម្រោងក្នុងរដូវក្តៅនោះក្តី

0:14

គឺខ្ញុំមានការរីករាយបង្ហាញសិក្ខាសាលារដូវក្តៅ

0:16

ប្រចាំឆ្នាំរបស់យើងក្នុងក្រុង ឡុងប៊ីច

0:18

ដែលអ្នកនឹងរៀនអំពី

0:20

កម្មវិធី និងឱកាសប្លែកៗដែលមាន

0:22

សម្រាប់អ្នក និងគ្រួសាររបស់អ្នក ។

0:24

ដូច្នេះ អ្វីទៅហៅ រដូវក្តៅក្នុងក្រុង ឡុងប៊ីច?

0:27

ក្នុងបទបង្ហាញនេះ

0:29

ខ្ញុំនឹងពន្យល់អំពីបាតុភូតមួយ ហៅថា "ភាពធ្លាក់ចុះក្នុងរដូវក្តៅ"

0:32

និងអ្វីដែលអ្នកអាចធ្វើបានក្នុងនាមជាមាតាបិតា ឬ អ្នកមើលខុសត្រូវ

0:35

សម្រាប់ជួយយុវវ័យរបស់អ្នក ។

0:37

ខ្ញុំនឹងបង្ហាញសកម្មភាព និងព្រឹត្តិការណ៍សំខាន់ខ្លះៗ

0:40

និងណែនាំកន្លែងចូលរួមក្នុងព្រឹត្តិការណ៍ទាំងអស់នេះ និងអ្វីច្រើនទៀត ។

0:44

គោលគំនិតអំពីភាពធ្លាក់ចុះក្នុងរដូវក្តៅ

0:47

គឺស្ថិតក្រោមការតាមដានមើលរបស់អ្នកស្រាវជ្រាវតាំងពីឆ្នាំ1996 មក ។

0:51

ការសិក្សាស្រាវជ្រាវបានបង្ហាញថា

0:53

សិស្សមានអាយុរៀននៅតាមសាលាបឋមសិក្សា

0:55

បាត់បង់ចំណេះច្រើនណាស់ក្នុងផ្នែកអាន និងគណិតសាស្ត្រ

0:58

នៅពេលសម្រាករដូវក្តៅ ។

1:00

សិស្សមានអាយុតូចៗក្នុងថ្នាក់មេត្តយ្យ ដល់ថ្នាក់ទី3

1:03

ច្រើនតែទទួលបាត់បង់ការរៀន

1:06

ដោយមូលហេតុថា ពួកគេស្ថិតនៅក្នុងវគ្គសំខាន់មួយអំពីផ្នែកធំលូតលាស់របស់ពួកគេ ។

1:10

អ្វីដូចជា៖ រៀនប្រែប្រកបពាក្យ ចំណេះតួអក្សរ

1:13

ការអាន និងជំនាញគណិតសាស្ត្រ

1:15

គឺអាចធ្លាក់ចុះ ដោយគ្មានការអនុវត្តន៍ញឹកញាប់ ។

1:18

ប៉ុន្តែ នៅមានកិច្ចការងាយៗខ្លះៗ

1:21

ដែលមាតាបិតា និងអ្នកមើលខុសត្រូវអាចធ្វើបាន

1:23

ដើម្បីការពារភាពធ្លាក់ចុះក្នុងរដូវក្តៅ ។

1:25

មធ្យោបាយទីមួយ គឺធ្វើអោយសិស្សចូលរួមក្នុងការអាន ។

1:30

រដូវក្តៅ គឺជាពេលពិសេស ដើម្បីអោយសិស្សអានអំពីអ្វី ដែលគេចង់អាន

1:34

និងស្របតាមចំណូលចិត្ត ឬ កិច្ចការពេញចិត្តធ្វើរបស់គេ ។

1:37

ជជែកជាមួយសិស្សរបស់អ្នកអំពីអ្វី ដែលគេកំពុងអាន ។

1:41

សួរគេមើល ដើម្បីអោយពន្យល់ប្រាប់អ្នក ឬ សមាជិកក្នុងគ្រួសារ ។

1:45

ការកត់ទុកកំណត់ហេតុ គឺជាមធ្យោបាយល្អពិសេស ដើម្បីបង្កើនជំនាញផ្នែកសរសេរ ។

1:50

បើគម្រោងរដូវក្តៅរបស់អ្នក មានរាប់ទាំងការធ្វើដំណើរកំសាន្តនោះផង

1:52

គឺសូមប្រាប់គេអោយកត់ទុកអំពីសកម្មភាព និងបទពិសោធន៍ប្រចាំថ្ងៃ

1:56

នៅក្នុងកូនសៀវភៅមួយ ។

1:57

នេះនឹងរក្សាទុកនូវអនុស្សាវរីយ៍ដ៏ពេញចិត្តអំពីការធ្វើដំណើររបស់អ្នក ។

2:01

មធ្យោបាយទីពីរ គឺប្រើពេលសម្រាប់ការលេងជាគំនិតឆ្លាត ។

2:05

ល្បែងលេង និងល្បែងរៀបដាក់ជាសន្លឹកបន្ទះៗអាចជួយធ្វើអោយខួរក្បាលដើរលឿនល្អ

2:07

និងបង្កើនចំណេះប្រើពាក្យ ។

2:09

ល្បែង ឌីជីថល គឺពិសេស

2:11

ប៉ុន្តែ ល្បែងលេង ដោយគ្មាន ឌីជីថល គឺកាន់តែប្រសើរជាង ។

2:14

រៀបចំទុកពេលក្នុងសប្តាហ៍សម្រាប់ជាពេលគ្រួសារលេងល្បែងជុំគ្នា

2:18

ជាមួយល្បែងក្តារ សន្លឹកបៀរ

2:20

និងបន្ថែមទាំងល្បែងលេងក្រៅផ្ទះ ។

2:22

ល្បែងបង្ហាត់អំពីតម្លៃក្នុងការធ្វើអ្វីរួមគ្នាជាក្រុម និងការដោះស្រាយបញ្ហា ។

2:26

អ្នកប្រហែលជានឹងមានការភ្ញាក់ផ្អើល

2:28

អំពីការពេញចិត្តនៃកូនៗរបស់អ្នកមកលើការលេងល្បែង ។

2:30

មធ្យោបាយទីបី គឺទាក់ទងកិច្ចការក្រៅផ្ទះ ។

2:34

អ្នកជំនាញការបានរកឃើញថា កិច្ចការក្រៅផ្ទះ

2:36

ជួយបណ្តុះខួរក្បាល និងបង្កើននូវការរៀន ។

2:40

ទៅពិនិត្យទីតាំងប្រវត្តិសាស្ត្រពិសេសៗ

2:42

ឬគ្រាន់តែអានសៀវភៅជុំគ្នាក្នុងសួន

2:44

គឺអាចជួយកូនរបស់អ្នកអោយមានការពេញចិត្តកាន់តែច្រើន

2:46

អំពីការអាន និងការរៀន ។

2:48

អ្នកអាចទៅពិនិត្យទីតាំងជាក់លាក់ណាមួយបានផងដែរ

2:51

ដែលទាក់ទាញទឹកចិត្តចេញពីសៀវភៅដែលអ្នកបានអានអំពីជុំគ្នា ។

2:54

នេះជួយរំលឹកឡើងវិញអំពីអ្វីដែលក្មេងៗកំពុងតែរៀន

2:57

មកពីសៀវភៅស្របតាមទីតាំងផ្ទាល់ពិតប្រាកដ ។

2:59

ទាក់ទងក្រុមមិត្តភ័ក្ត

3:01

និងជួបគ្នាក្នុងសួន ដើម្បីលេងល្បែង ឬ ហាត់ប្រាណ ។

3:05

ការជួបជុំគ្នានៅក្នុងសួន និងឆ្នេរសមុទ្រជាច្រើនរបស់យើង

3:08

គឺជាមធ្យោបាយពិសេស ដើម្បីចំណាយពេលមានប្រយោជន៍រួមគ្នា ។

3:12

មធ្យោបាយទីបួន គឺទាក់ទង

3:14

ការប្រើគំនិតនឹកគិត និងការឆ្នៃប្រឌិត ។

3:17

រៀនជំនាញថ្មីៗដែលអ្នកតែងតែនឹកចង់សាកល្បងធ្វើ ។

3:21

ការស្វែងរកកិច្ចការថ្មីៗស្របចំណូលចិត្តដែលជាកិច្ចការអ្នកពេញចិត្តធ្វើ ។

3:24

លេងល្បែងដែលអ្នកដឹងរបៀបលេងរួចមកហើយ

3:26

និងបង្កើតល្បែងថ្មី ឬ កំណែថ្មីអំពីល្បែងនោះ ។

3:30

ការបង្ហាញគំនិតទាំងអស់នេះអាចបង្កើនជំនឿទុកចិត្តក្នុងខ្លួន

3:33

និងបង្កើនជំនាញផ្នែកដោះស្រាយបញ្ហា និងការធ្វើទំនាក់ទំនង

3:37

ហើយក៏អាចជួយបណ្តុះដៃរនូវភាពពិសេស និងភាពចម្រុះផ្សេងៗរបស់ក្មេង ។

3:41

អូយេ យើងបានពន្យល់ហើយអំពីភាពធ្លាក់ចុះក្នុងរដូវក្តៅ

3:44

និងបានផ្តល់ជាគំនិតខ្លះៗជូនអ្នក

3:46

អំពីមធ្យោបាយដែលអ្នកអាចការពារ ដើម្បីកុំអោយមានភាពធ្លាក់ចុះកើតឡើងបាន ។

3:50

នៅពេលនេះ យើងចង់ផ្តល់ជូនអ្នកអំពីធនធានខ្លះៗ

3:53

និងអង្គការផ្សេងៗដែលបើកផ្តល់សកម្មភាព

3:56

ជូនអ្នក និងសិស្សរបស់អ្នក ។

3:58

តើអ្នកគិតថា រដូវក្តៅក្នុងក្រុង ឡុងប៊ីច គឺសម្រាប់តែក្មេងៗ មែនទេ?

4:01
យើងមានគំនិតខ្លះៗ ដើម្បីទាក់ទាញគ្រួសារទាំងមូលអោយចូលរួមជាមួយគ្នា ។
4:05
យើងបានរៀបចំអំពីការផ្តល់ជូនរបស់យើងជា បី ចំណែកៈ
4:09
ក្មេងៗ គ្រួសារ និង មាតាបិតា ។
4:12
ការផ្តល់ជូនខ្លះៗ គឺសម្រាប់តែក្មេងៗប៉ុណ្ណោះ
4:15
ហើយការផ្តល់ជូនផ្សេងៗទៀតអាចមានជាកម្មវិធីបំប៉ន និងធនធានសម្រាប់មាតាបិតា ។
4:19
ទីបំផុត មានការផ្តល់ជូនសម្រាប់គ្រួសារទាំងមូល
4:22
ដើម្បីទទួលនូវការសប្បាយជុំគ្នា ។
4:24
ក្នុងគេហទំព័រ Parent University របស់យើង
4:26
គឺអ្នកនឹងឃើញបទបង្ហាញនេះដាក់តាំងសម្រាប់ការដកស្រង់ប្រើតាមទៅថ្ងៃមុខ ។
4:30
ប៉ុន្តែ សំខាន់ច្រើនជាងនេះទៅទៀត
4:32
គឺមានបណ្តាញនៅខាងក្រោមរាយទៅកាន់ spreadsheet ។
4:34
នៅពេលអ្នកចុចក្នុងបណ្តាញ
4:36
គឺ spreadsheet ដូចតទៅនឹងបង្ហាញ ។
4:39
នៅតាមជួរទីមួយ គឺមានឈ្មោះបញ្ជីអង្គការ ។
4:42
នៅតាមជួរទីពីរ គឺមានឈ្មោះបែងចែកតាមចំណែកៈ
4:45
ក្មេងៗ គ្រួសារ ឬ មាតាបិតា ។
4:48
ជួរបន្ទាប់ទៀត គឺបង្ហាញអ្នកអំពីការរៀបរាប់ខ្លីៗ

4:51

អំពីអង្គការ ឬ សកម្មភាព ។

4:54

បន្ទាប់មក អ្នកនឹងស្វែងឃើញអំពីបណ្តាញទៅកាន់គេហទំព័រ

4:56

និងព័ត៌មានដែលអ្នកអាចទាក់ទងបាន

4:58

បើអ្នកត្រូវការព័ត៌មានបន្ថែម ។

5:01

Spreadsheet នេះនឹងដាក់បង្ហាញព័ត៌មានថ្មីៗញឹកញាប់

5:03

ពីពេលនេះរហូតដល់ពេលចុងបញ្ចប់ឆ្នាំសិក្សា ។

5:06

អូយេ ចូរនាំគ្នាតាមដានមើល ។

5:09

LBUSD បើកផ្តល់កម្មវិធីសម្រាប់ក្មេងៗ ហៅ WRAP ។

5:13

នេះជាការបើកផ្តល់ជូនក្នុងពេលរៀនក្នុងឆ្នាំសិក្សានៅតាមសាលារៀនភាគច្រើន

5:17

ប៉ុន្តែ អ្នកប្រហែលជាមិនបានដឹងទេថា

5:18

នេះក៏មានបើកផ្តល់ជូនដែរក្នុងពេលរដូវក្តៅ ។

5:21

WRAP គឺជាអក្សរកាត់សម្រាប់ Winners Reaching Amazing Potential ។

5:26

នេះជាកម្មវិធីបើកផ្តល់ជូនគ្រួសារ LBUSD ដោយមិនបង់លុយ

5:30

និងបើកផ្តល់ជូននៅតាមសាលារៀនជាទីតាំងងាយប្រើទូទាំងមណ្ឌលអប់រំ ។

5:34

ក្នុងកម្មវិធីនេះ គឺមានកម្មវិធីបំប៉នផ្នែកសិក្សា

5:37

រួមទាំងសកម្មភាពបញ្ចេញកម្លាំងកាយ និងថែទាំសុខភាពអារម្មណ៍ ។

5:41

អ្នកអាចចុចក្នុងបណ្តាញនៅខាងក្រោម

5:43

ដើម្បីបើកមើលបានអំពីបណ្ណិក្នុងគេហទំព័រ ។

5:46

មណ្ឌលអប់រំរបស់យើងក៏បើកផ្តល់ជូនដែរអំពីកម្មវិធីផ្ញើក្មេង ហៅ Kids' Club ។

5:50

នេះជាកម្មវិធីបង់លុយ

5:52

ដែលបើកផ្តល់ជូនជាកម្មវិធីបំប៉នផ្នែកសិក្សា

5:55

និងសកម្មភាពទាក់ទងការបញ្ចេញកម្លាំងកាយ និងថែទាំសុខភាពអារម្មណ៍

5:58

នៅតាមការងាយស្រួលយកទៅផ្ញើ បី កន្លែង ។

6:01

ប្រធានបទសម្រាប់ឆ្នាំនេះ គឺ Animal Kingdom ។

6:04

សូមលៃលកពិនិត្យមើលអំពី WRAP និង Kids' Club

6:07

ក្នុងគេហទំព័ររបស់យើង ។

6:09

អ្នកទាំងអស់គ្នាភាគច្រើនប្រហែលជាបានទទួល

6:11

សៀវភៅនេះហៅ Recreation Connection ក្នុង អ៊ីម៉េល រួចមកហើយ

6:14

ពីក្រសួង Parks, Recreation និង Marine ប្រចាំក្រុង ឡុងប៊ីច

6:19

វាមានការរាយបង្ហាញអំពីសកម្មភាពគ្រប់យ៉ាង

6:22

រាប់បញ្ចូលផងទាំងកម្មវិធីបោះជំរុំ ថ្នាក់រៀនផ្សេងៗ

6:25

កម្មវិធីកីឡា កម្មវិធីផ្សេងៗក្នុងសួន

6:28

ពេលចូលហែលទឹក បើកទូកក្តោង និងការលេងកីឡាធីនិស ។

6:32
បើអ្នកមិនទាន់បានទទួលសៀវភៅនេះនៅឡើយ
6:34
សូមកុំខ្វល់ខ្វាយអោយសោះ ។
6:35
យើងនឹងលើកបង្ហាញចំណុចសំខាន់ៗខ្លះៗអំពីសកម្មភាពជូនអ្នក ។
6:38
សូមចុចលើរូប
6:39
ឬ ស្វែងរកសៀវភៅភ្ជាប់ទៅកាន់ spreadsheet របស់យើង ។
6:42
នេះជាចំណុចសំខាន់ៗខ្លះៗមកពីសៀវភៅនោះ ។
6:46
YMCA ប្រចាំតំបន់របស់អ្នកបើកផ្តល់កម្មវិធីបោះជំរុំពេលថ្ងៃជូនគ្រួសារ ។
6:50
កម្មវិធីបោះជំរុំទាំងអស់នេះត្រូវបង់លុយ
6:52
ប៉ុន្តែ អាចមិនត្រូវបង់លុយទេសម្រាប់គ្រួសារមានប្រាក់ចំណូលទាប ។
6:55
សកម្មភាព គឺមានដូចជា៖ ការធ្វើដំណើរ
6:58
មេរៀនហែលទឹក
6:59
និងសិក្ខាសាលាមាតាបិតា ដែលនៅមានបន្ថែមទៀត ។
7:03
មានសាខា YMCA ប្រាំមួយកន្លែងក្នុង ឡុងប៊ីច ដើម្បីសម្រួលកិច្ចការជូនអ្នក ។
7:08
សួនប្រចាំក្រុង ឡុងប៊ីច បើកផ្តល់សកម្មភាពផ្សេងៗសម្រាប់ក្មេងៗ ។
7:11
សកម្មភាពខ្លះត្រូវបង់លុយ
7:13
និងខ្លះទៀត គឺជាកម្មវិធីបោះជំរុំដែលជាការជម្រើសចូលរួមសម្រាប់ក្មេងៗ ។
7:16
ស្នើសុំអោយមានការចុះឈ្មោះទុក

7:18
ដូច្នេះ សូមអ្នកទៅពិនិត្យសួនប្រចាំតំបន់របស់អ្នក
7:20
ដើម្បីទទួលព័ត៌មានបន្ថែមអំពីមធ្យោបាយចុះឈ្មោះសម្រាប់កូនរបស់អ្នក ។
7:24
មាន ប្រាំមួយ សួនក្នុងក្រុង ឡុងប៊ីច របស់យើងដែលបើកផ្តល់ជាមជ្ឈមណ្ឌលយុវវ័យ ។
7:27
ពីម៉ោង 12:00 រសៀល ទៅ to 6:00 ល្ងាច
7:30
យុវវ័យរបស់អ្នកអាចពិនិត្យដល់កន្លែងបាន
7:31
ដើម្បីចូលរួមក្នុងសកម្មភាពកំសាន្ត ឬ ទទួលជំនួយពីអ្នកស្ម័គ្រ
7:34
អំពីកិច្ចការ ហូមវើក
7:36
ការប្រជែងកីឡា និងថ្នាក់ហាត់ប្រាណ ។
7:39
បើអ្នកស្វែងរកកន្លែងសម្រាប់ដាក់គ្រួសារទាំងមូលចូលរួម
7:42
គឺសូមទៅពិនិត្យ Ranchos របស់យើង ។
7:44
ផ្ទះប្រវត្តិសាស្ត្រទាំងអស់នេះមានទេសភាពស្អាត
7:47
ដែលមានអ្នកនាំដើរពន្យល់ក្នុងទីដីផ្ការផ្ទាល់ ។
7:51
វាជាកន្លែងបន្ធូរអារម្មណ៍ និងដើរកំសាន្ត
7:54
តាមរយៈទីដីផ្ការ ដើម្បីរៀនអំពី
7:56
ប្រវត្តប្រចាំតំបន់របស់ Ranchos ។
7:58
ក្នុងខែរដូវក្តៅ
8:00
គឺមានកម្មវិធីបើកផ្តល់ជូនច្រើន ។

8:02

សូមអ្នកលែលកបើកមើល ។

8:04

សកម្មភាពសប្បាយៗផ្សេងមួយទៀតសម្រាប់គ្រួសារ

8:06

គឺការបញ្ចាំងភាពយន្តក្នុងសួន ។

8:08

ឆ្នាំនេះ ការបញ្ចាំងភាពយន្តទាំងអស់ក្នុងរដូវក្តៅ

8:11

គឺអាចស្វែងរកបានក្នុងសៀវភៅកម្មវិធីកំសាន្ត

8:13

ប៉ុន្តែ យើងមានកាលវិភាគក្នុងទីនេះសម្រាប់អ្នកផងដែរ ។

8:17

ភាពយន្តទាំងអស់នឹងបញ្ចាំងនៅពេលព្រលប់ ។

8:19

រៀបចំភួយ និងប្រដាប់ប្រដាផ្សេងៗសម្រាប់ ពិចនិច

8:21

និងធ្វើដំណើរទៅសួន ដើម្បីទទួលការសប្បាយអស្ចារ្យខ្លះៗ ។

8:25

ក្រុមតន្ត្រីប្រចាំក្រុង ឡុងប៊ីច

8:27

នឹងអបអរខួបរដូវទី 114 ក្នុងឆ្នាំនេះ

8:30

ដោយធ្វើការប្រគុំមិនគិតថ្លៃក្នុងសួននានាប្រចាំក្រុង ឡុងប៊ីច

8:34

ពីខែមិថុនា ទី27 ទៅ ខែសីហា ទី4

8:37

ដោយរៀបដាក់ជាប្រធានបទប្លែកៗរាល់សប្តាហ៍ ។

8:40

មនុស្សជិតខាង និងគ្រួសារអាចមកជុំគ្នា

8:42

ក្នុងរាត្រីពោរពេញដោយបទតន្ត្រីពីរោះៗ

8:44

នៅក្នុងសហគមន៍ទាំងអស់គ្នា ។

8:46

មាតាបិតា និងអ្នកមើលខុសត្រូវនឹងមានឱកាស

8:48

ដើម្បីបញ្ចេញសកម្មភាពផងដែរ ។

8:50

មានចំណែកមួយ

8:51

នៅក្នុងសៀវភៅ Recreation Connection គឺសម្រាប់តែអ្នក ។

8:55

ថ្នាក់របាំ យ៉ូហ្គា

8:57

ការកម្រើកដងខ្លួន ថ្នាក់ Zumba និងថ្នាក់ហាត់ប្រាណសម្រាប់មនុស្សចាស់

9:01

រួមទាំងថ្នាក់បំប៉នផ្សេងៗដែលមានបើកផ្តល់ជូនផងដែរ ។

9:04

សូមបើកមើលកាលវិភាគពេញលេញអំពីថ្នាក់ផ្សេងៗ

9:06

ដែលមានបើកផ្តល់ជូនក្នុងសៀវភៅ ។

9:09

តើអ្នកណាអាចបំភ្លេចបានអំពីបណ្ណាល័យសាធារណៈរបស់យើង?

9:11

មិនត្រឹមតែយើងអាចខ្ចីសៀវភៅបាននោះទេ

9:14

គឺបណ្ណាល័យសាធារណៈ ឡុងប៊ីច មានទាំងគេហទំព័រដ៏អស្ចារ្យផង

9:17

ដែលមានកម្មវិធីបើកផ្តល់ជូនជាច្រើនប្លែកៗសម្រាប់មនុស្សទាំងអស់ ។

9:21

ក្នុង មីនូ LEARN ជាពិសេស គឺមានប្រយោជន៍ណាស់ ។

9:25

សម្រាប់កុមារ និងយុវវ័យ

9:26

គឺមានក្រុមផ្សេងៗ

9:28

ជំនួយពន្យល់កិច្ចការ ហូមវើក

9:29

ការត្រៀមរៀបចំសម្រាប់មហាវិទ្យាល័យ និងអាហារូបករណ៍ ។

9:32

មនុស្សធំអាចស្វែងឃើញព័ត៌មានបានអំពីក្រុមផ្សេងៗ

9:36

វិទ្យាល័ញអាជីព អនឡាញ

9:38

ក្លិប សៀវភៅ និងព័ត៌មានជាជំនួយសម្រាប់ទាហានជើងចាស់ ។

9:42

មនុស្សទាំងអស់អាចមានសិទ្ធិ ដើម្បីទទួលធនធាន អនឡាញ

9:45

podcasts ការប្រើ កុំព្យូទ័រ និងការព្រិនក្រដាស

9:48

រួមទាំងការប្រើមជ្ឈមណ្ឌលសិក្សាសម្រាប់គ្រួសារបាន ។

9:51

ពិតមែនហើយ មានព័ត៌មានច្រើនណាស់

9:53

ប៉ុន្តែ ពេលនេះ គឺអ្នកដឹងហើយអំពីសកម្មភាពផ្សេងៗក្នុងរដូវក្តៅ

9:55

ដែលបើកផ្តល់ជូននៅទូទាំងទីក្រុងរបស់យើង

9:57

រួមទាំងការដឹងទៀតផងដែរអំពីកន្លែងស្វែងរកធនធានផ្សេងៗ

10:00

ដើម្បីទទួលព័ត៌មានបានកាន់តែច្រើន

10:02

សូមកុំភ្លេចចូលពិនិត្យគេហទំព័រ Parent University របស់យើង

10:05

សម្រាប់ការថតបង្ហាញនេះ

10:06

និងដើម្បីបើកចូលទៅកាន់ spreadsheet រដូវក្តៅក្នុងក្រុង ឡងប៊ីច

10:10

វានឹងមានព័ត៌មានថ្មីៗបង្ហាញរហូតដល់ចុងខែមិថុនា ។

10:13

ជាកត្តិយសរបស់ខ្ញុំក្នុងការចែករំលែកធនធានទាំងអស់នេះជូនអ្នក ។

10:17

សូមអញ្ជើញទាក់ទងយើងតាមទូរស័ព្ទ ឬ អ៊ីម៉ែល

10:20

បើអ្នកមានសំណួរផ្សេងៗណាមួយ ។

10:22

ផ្ញើ អ៊ីម៉ែល របស់អ្នកទៅកាន់ ParentU@lbschools.net

10:27

ឬ តាមទូរស័ព្ទលេខ 562 997-8106 ។

10:33

ក្នុងនាមជាអ្នកតំណាងអោយក្រសួងរបស់យើង

10:35

ខ្ញុំសូមជូនពរក្នុងការទទួលភាពសប្បាយពេលរដូវក្ដៅ ។

10:36

សូមចេញក្រៅផ្ទះ និងទទួលភាពសប្បាយខ្លះៗ ។